ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SECURITIES AND EXCHANGE REGULATOR OF CAMBODIA

**និយ័តករមូលបត្រកម្ពុជា**

លេខ: ០០៣/២២ ន.ម.ក./គ.ល.ស.

# គោលការណ៍ណែនាំ

# ស្តីពី

# ការបោះផ្សាយលក់សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម និងសញ្ញាបណ្ណនិរន្តរភាព

អនុលោមតាមច្បាប់ស្តីពីរៀបចំនិងការប្រព្រឹត្តិទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១, ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជនដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧, អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០៩/១៧ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០១៧ ស្តីពីការបោះផ្សាយលក់មូលបត្រប៊ីណុលជាសាធារណៈ និងប្រកាសលេខ ០០៦/២០ គ.ម.ក./ប្រ.ក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ ២០២០ ស្តីពីការបោះផ្សាយលក់មូលបត្រប៊ីណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹងក្នុងការបោះផ្សាយលក់សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម និងសញ្ញាបណ្ណនិរន្តរភាពប្រកបដោយប្រសិទ្ធភាព និយ័តករមូលបត្រកម្ពុជា(**ន.ម.ក.**) ដាក់ចេញគោលការណ៍ណែនាំស្តីពីការបោះផ្សាយលក់សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម និងសញ្ញាបណ្ណនិរន្តរភាពដូចខាងក្រោម÷

## ១-សញ្ញាណទូទៅនៃសញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម និងសញ្ញាបណ្ណនិរន្តរភាព

### ១.១. សញ្ញាបណ្ណបៃតង

សញ្ញាបណ្ណបៃតង សំដៅដល់មូលបត្រប៊ីណុលដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុនបោះផ្សាយមូលបត្រ ហើយសាច់ប្រាក់ដែលទទួលបានមកពីការបោះផ្សាយត្រូវបានប្រើប្រាស់ដើម្បីធ្វើហិរញ្ញប្បទាន ឬហិរញ្ញប្បទានឡើងវិញ ដល់គម្រោង ឬទ្រព្យសកម្មបៃតង។

**ឧទាហរណ៍÷** ការអភិវឌ្ឍគម្រោងបង្កើតថាមពលអគ្គិសនីដែលដំណើរការដោយកំលាំងខ្យល់ ឬពន្លឺព្រះអាទិត្យ ការទិញដីសម្រាប់សាងសង់ឬទិញសំភារៈបរិក្ខារទ្រទ្រង់ដល់ការផលិតថាមពលអគ្គិសនីដែលដំណើរការដោយកំលាំងខ្យល់ ឬពន្លឺព្រះអាទិត្យ ការអភិវឌ្ឍគម្រោងផលិតរថយន្តដែលដំណើរការដោយថាមពលអគ្គិសនី ជាដើម។

អាសយដ្ឋាន៖ អគារ 168F ផ្លូវ 598 សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ-កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Address: Building 168F, Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

**១.២. សញ្ញាបណ្ណសង្គម**

សញ្ញាបណ្ណសង្គម សំដៅដល់មូលបត្របំណុលដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុនបោះផ្សាយមូលបត្រ ហើយសាច់ប្រាក់ដែលទទួលបានមកពីការបោះផ្សាយត្រូវបានប្រើប្រាស់ដើម្បីធ្វើហិរញ្ញប្បទាន ឬហិរញ្ញប្បទានឡើងវិញ ដល់គម្រោងទាំងឡាយណាដែលជះឥទ្ធិពលវិជ្ជមានដល់សង្គម។

**ឧទាហរណ៍៖** ការផ្តល់ប្រាក់កម្ចីដល់សហគ្រាសធុនតូច និងមធ្យមដើម្បីជួយដល់សេដ្ឋកិច្ចសង្គម និងបង្កើតការងារ គម្រោងលើផ្នែកអប់រំ ការអភិវឌ្ឍគម្រោងទឹកស្អាតនិងអនាម័យនៅតាមទីជនបទដាច់ស្រយាល គម្រោងអប់រំសុខភាពសាធារណៈ ជាដើម។

**១.៣. សញ្ញាបណ្ណនិរន្តរភាព**

សញ្ញាបណ្ណនិរន្តរភាព សំដៅដល់មូលបត្របំណុលដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុនបោះផ្សាយមូលបត្រ ហើយសាច់ប្រាក់ដែលទទួលបានមកពីការបោះផ្សាយត្រូវបានប្រើប្រាស់ដើម្បីធ្វើហិរញ្ញ-ប្បទាន ឬហិរញ្ញប្បទានឡើងវិញ ដល់គម្រោងទាំងឡាយណាដែលមានបញ្ចូលគ្នានូវលក្ខណៈបៃតង និងសង្គម ដែលជះឥទ្ធិពលវិជ្ជមានដល់សង្គម និងបរិស្ថាន។

**ឧទាហរណ៍៖** ការអភិវឌ្ឍគម្រោងកែច្នៃកាកសំណល់ដែលជះឥទ្ធិពលវិជ្ជមានដល់បរិស្ថានផង និងសុខមាលភាពសង្គមផង ការអភិវឌ្ឍគម្រោងផ្តល់សេវាដឹកជញ្ជូនសាធារណៈក្នុងគោលដៅកាត់បន្ថយការប្រើប្រាស់យានយន្តផ្ទាល់ខ្លួន ការអភិវឌ្ឍគម្រោងបន្សុទ្ធខ្យល់ ជាដើម។

**២-គោលការណ៍សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម និងសញ្ញាបណ្ណនិរន្តរភាព**

បុគ្គលដែលមានបំណងបោះផ្សាយលក់សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព ត្រូវអនុវត្តគោលការណ៍ចំនួន ៤ (បួន) ដូចខាងក្រោម៖

**-គោលការណ៍ទី១៖ គោលបំណងនៃការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយ**

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវកំណត់ឱ្យបានច្បាស់លាស់ពីគោលបំណងនៃការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយឱ្យស្របទៅតាមស្តង់ដា ឬក្របខណ្ឌដែលពាក់ព័ន្ធនឹងសញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព ដែលបានកំណត់។

**-គោលការណ៍ទី២៖ ដំណើរការនៃការវាយតម្លៃ និងការជ្រើសរើសគម្រោង**

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវមានយន្តការ និងនីតិវិធីផ្ទៃក្នុងសមស្របដើម្បីធ្វើការវាយតម្លៃ និងជ្រើសរើសប្រភេទគម្រោង ឬទ្រព្យសកម្ម ដែលត្រូវប្រើប្រាស់សម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព។

**-គោលការណ៍ទី៣៖ ការចាត់ចែងសាច់ប្រាក់ដែលបានមកពីការបោះផ្សាយ**

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវចាត់ចែងសាច់ប្រាក់ដែលបានមកពីការបោះផ្សាយឱ្យបានត្រឹមត្រូវ និងស្របទៅតាមគោលបំណងដែលបានកំណត់ទុក។

**-គោលការណ៍ទី៤÷ ការរាយការណ៍**

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវរាយការណ៍ជូនវិនិយោគិនពី÷

ក- ការបែងចែងសាច់ប្រាក់ដែលបានមកពីការបោះផ្សាយទៅលើគម្រោង ឬទ្រព្យសកម្មដែលបានកំណត់។

ខ- លទ្ធភាពនៃការបំពេញបានតាមលក្ខខណ្ឌតម្រូវជាសញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញា-បណ្ណនិរន្តរភាព ស្របតាមស្តង់ដា ឬក្របខណ្ឌដែលបានអនុវត្ត។

គ- ផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានពាក់ព័ន្ធនឹងគម្រោងដែលបានអនុវត្ត ឬការប្រើប្រាស់ទ្រព្យសកម្ម ស្របតាមស្តង់ដា ឬក្របខណ្ឌដែលបានអនុវត្ត។

**៣- ការត្រួតពិនិត្យឯករាជ្យ**

ការត្រួតពិនិត្យឯករាជ្យ សំដៅដល់ដំណើរការនៃការពិនិត្យ និងវាយតម្លៃទៅលើអនុលោមភាពនៃគម្រោង ឬទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយអនុលោមតាមស្តង់ដា ឬក្របខណ្ឌដែលបានអនុវត្ត។ ក្រុមហ៊ុនបោះផ្សាយមូលបត្រ អាចទទួលបានការវាយតម្លៃលើប្រភេទ និងគម្រោង ឬទ្រព្យសកម្មនៃសញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព ដែលត្រូវធ្វើការបោះផ្សាយពីអ្នកត្រួតពិនិត្យឯករាជ្យ ហើយករណីដែលទទួលបានការវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវភ្ជាប់របាយការណ៍វាយតម្លៃនោះមកជាមួយពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុល។

ករណីក្រុមហ៊ុនបោះផ្សាយមូលបត្រ មានបំណងទទួលបានការដាក់ឈ្មោះសញ្ញាបណ្ណថាជាប្រភេទបៃតង សង្គម ឬនិរន្តរភាព នោះក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវទទួលបានការវាយតម្លៃពីអ្នកត្រួតពិនិត្យឯករាជ្យ ដោយអាស្រ័យទៅតាមស្តង់ដា ឬក្របខណ្ឌដែលបានអនុវត្ត។

**៣.១. ទម្រង់នៃការត្រួតពិនិត្យឯករាជ្យ**

ការត្រួតពិនិត្យឯករាជ្យអាចធ្វើឡើងជា ៤ ទម្រង់ ដូចខាងក្រោម÷

**ក- យោបល់របស់អ្នកផ្តល់ប្រឹក្សា ឬស្ថាប័នជំនាញ**

ក្រុមហ៊ុនបោះផ្សាយមូលបត្រអាចស្វែងរកការផ្តល់យោបល់ ឬអនុសាសន៍ពីអ្នកផ្តល់ប្រឹក្សា ឬស្ថាប័នជំនាញ ដែលជាស្ថាប័នឯករាជ្យពីក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ការស្វែងរកការផ្តល់យោបល់ ឬអនុសាសន៍នេះ ជាការវាយតម្លៃទៅលើ÷

-អនុលោមភាពជាមួយនឹងគោលការណ៍សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណ និរន្តរភាព

-គោលបំណង យុទ្ធសាស្ត្រ គោលនយោបាយ និង/ឬដំណើរការរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រដែលពាក់ព័ន្ធនឹងភាពបៃតង សង្គម ឬនិរន្តរភាព

-ប្រភេទគម្រោងដែលមានលក្ខណៈបៃតង សង្គម ឬនិរន្តរភាព ដែលត្រូវធ្វើហិរញ្ញប្បទានដោយប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយ។

**ខ- ការបញ្ជាក់ពីភាពបៃតង សង្គម ឬនិរន្តរភាព**

ក្រុមហ៊ុនបោះផ្សាយមូលបត្រអាចទទួលបានការបញ្ជាក់អំពីអនុលោមភាពតាមស្តង់ដា ឬការកំណត់ប្រភេទបៃតង សង្គម ឬនិរន្តរភាពដែលទទួលបានការទទួលស្គាល់ពីអ្នកត្រួតពិនិត្យឯករាជ្យ។

**គ-ការផ្ទៀងផ្ទាត់**

ក្រុមហ៊ុនបោះផ្សាយមូលបត្រអាចទទួលបានការផ្ទៀងផ្ទាត់ដោយអ្នកត្រួតពិនិត្យឯករាជ្យពាក់ព័ន្ធនឹងដំណើរការអាជីវកម្ម និង/ឬលក្ខណៈវិនិច្ឆ័យជាប្រភេទបៃតង សង្គម ឬនិរន្តរភាព។ ការផ្ទៀងផ្ទាត់នេះអាចផ្តោតទៅលើអនុលោមភាពតាមស្តង់ដា ឬក្របខណ្ឌបៃតង សង្គម ឬនិរន្តរភាព។

**ឃ-ការដាក់ពិន្ទុ ឬចំណាត់ថ្នាក់**

សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព ឬក្របខណ្ឌសញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ អាចទទួលរងការវាយតម្លៃថាជាប្រភេទបៃតង សង្គម ឬនិរន្តរភាព ដោយភាគីទីបីដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ដែលរួមមាន ភ្នាក់ងារវាយតម្លៃលទ្ធភាពសង ឬក្រុមហ៊ុនផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.**។

**៣.២.អ្នកត្រួតពិនិត្យឯករាជ្យ**

អ្នកត្រួតពិនិត្យឯករាជ្យ សំដៅដល់បុគ្គលដែលមានឯករាជ្យភាពពីក្រុមហ៊ុនបោះផ្សាយមូលបត្រ និងមានតួនាទីក្នុងការវាយតម្លៃលើប្រភេទគម្រោង ឬទ្រព្យសកម្ម ដែលត្រូវប្រើប្រាស់សាច់ប្រាក់ទទួលបានមកពីការបោះផ្សាយលក់សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព សម្រាប់ធ្វើហិរញ្ញប្បទាន ឬហិរញ្ញប្បទានឡើងវិញ។ អ្នកត្រួតពិនិត្យឯករាជ្យអាចជាអ្នកជំនាញផ្នែកបរិស្ថាន ផ្នែកសង្គម ឬជំនាញជាក់លាក់ណាមួយ។

**៤-ការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន**

បុគ្គលដែលមានបំណងបោះផ្សាយលក់សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព ត្រូវអនុវត្តអនុលោមតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ករណីបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ និងប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ ករណីបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងត្រូវបំពេញបន្ថែមនូវការអនុវត្តតាមគោលការណ៍ណែនាំលម្អិតស្តីពីការបោះផ្សាយលក់សញ្ញាបណ្ណបៃតងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្តង់ដាសញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព របស់អាស៊ាន (ASEAN GREEN BOND STANDARDS, ASEAN SOCIAL BOND STANDARDS AND ASEAN SUSTAINABILITY BOND STANDARDS) ឬស្តង់ដាអន្តរជាតិផ្សេងទៀតដែលពាក់ព័ន្ធនឹង សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម ឬសញ្ញាបណ្ណនិរន្តរភាព ដែលមានជាធរមាន។

ថ្ងៃ ច័ន្ទ ១៤រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០២២

**និយ័តករមូលបត្រកម្ពុជា**